March 8, 2019

# គណៈប្រតិភូអឺរ៉ុបនឹងមកទស្សនកិច្ចកម្ពុជា ដើម្បីប្រមូលព័ត៌មានមុនសម្រេចរឿង EBA



ជំនួបជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម@ក្រសួងពាណិជ្ជកម្ម

ដោយ រ៉ា សំណាង07/03/2019 rfi

គណៈប្រតិភូសហភាពអឺរ៉ុបនឹងមកទស្សនកិច្ចនៅកម្ពុជានៅចុងខែមីនា ឬ ដើមខែមេសាខាងមុខនេះ ដើម្បីប្រមូលយកព័ត៌មានពីប្រទេសកម្ពុជា មុនពេលពួកគេសម្រេចថា នឹងដក ឬ ព្យួរ ប្រព័ន្ធអនុគ្រោះពន្ធ EBA ពីប្រទេសកម្ពុជា ។ សូមជំរាបជូនថា កាលពីថ្ងៃទី ១៣ មករា ឆ្នាំ ២០១៩នេះ សហភាពអឺរ៉ុប បានប្រកាសពីការផ្ដើមនីតិវិធីនៃការសម្រេចចិត្តរបស់ខ្លួន ក្នុងការ ដក ឬ ព្យួរ EBA ពីកម្ពុជា ដោយផ្អែកលើការស្ថាលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា។

ដំណឹងនៃការមកដល់របស់គណៈប្រតិភូគណៈកម្មការអឺរ៉ុបនៅកម្ពុជានេះ ត្រូវបានទម្លាយឲ្យដឹងពីលោក ចច អេដហ្គា (George Edgar) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា នៅក្នុងជំនួបជាមួយលោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា កាលពីថ្ងៃទី ០៦ មីនា។ នៅក្នុងជំនួបនោះ លោក ចច អេដហ្គា (George Edgar)

*បានអះអាងថា នៅក្នុងអំឡុងពេលចុងខែមីនា និងខែមេសាខាងមុខនេះ ក្រុមការងារគណៈកម្មការអឺរ៉ុបមួយក្រុម នឹងមកបំពេញបេសកកម្មនៅកម្ពុជា។ ប៉ុន្តែលោកមិនទាន់អាចបញ្ជាក់ឲ្យបានច្បាស់ អំពីកាលបរិច្ឆេទនៅថ្ងៃណានៅឡើយទេ។ នៅក្នុងជំនួបជំរាបលានេះ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបង្ហាញពីការចង់ដឹង អំពីដំណើរការបន្ទាប់របស់សហភាពអឺរ៉ុប ក្រោយពីបានចាប់ផ្តើមនៃនីតិវិធីពិនិត្យការព្យួរជាបណ្តោះអាសន្ន នូវប្រព័ន្ធអនុគ្រោះពន្ធ* EBA *ពីកម្ពុជា ជាពិសេសពីបេសកកម្មនានារបស់គណៈកម្មការអឺរ៉ុបក្នុងដំណាក់កាល៦ខែដំបូង។*

*គួរជំរាបជូនថា សហភាពអឺរ៉ុប កាលពីថ្ងៃទី ១៣ មករា ឆ្នាំ ២០១៩នេះ បានប្រកាសពីការចាប់ផ្តើមនីតិវិធីនៃការសម្រេចចិត្តរបស់ខ្លួន ក្នុងការ ដក ឬ ព្យួរ ប្រព័ន្ធអនុគ្រោះពន្ធ* EBA *ពីកម្ពុជា បន្ទាប់ពីបានផ្តល់អនុសាសន៍ឲ្យកម្ពុជាស្តារឡើងវិញ នូវលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សអស់ជាច្រើនខែរួចមក។ ប៉ុន្តែយ៉ាងណាក៏ដោយ ផ្អែកតាមនីតិវិធីនេះ កម្ពុជានៅមានរយៈពេលដល់ទៅ១៨ខែទៀត ដើម្បីស្តារឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនេះ ដោយ ៦ខែដំបូង គឺស្ថិតនៅក្នុងដំណាក់កាលនៃការប្រមូលព័ត៌មាន។*
*សហភាពអឺរ៉ុបដែលបានរិះគន់រដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការរំលាយគណបក្សប្រឆាំង និងការចាប់ខ្លួនអតីតប្រធានគណបក្សប្រឆាំង លោក កឹម សុខា ដាក់ពន្ធនាគារតាំងពីខែកញ្ញា ឆ្នាំ ២០១៧ មកម្លេះ។ ដោយឡែកកាលពីថ្ងៃទី៩ មីនា ប្រមុខការទូតកម្ពុជា លោក ប្រាក់ សុខុន បានរិះគន់សហភាពអឺរ៉ុប អំពីដំណើរការសម្រេចត្រួតពិនិត្យ* EBA *ពីកម្ពុជា និងបានហៅដំណើរការនេះថា «គឺជាការអនុវត្តន៍ នូវស្តង់ដារពីរ មកលើកម្ពុជា»។*